ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៩៦ សហវ

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៨

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការរំលឹកអំពីកាលបរិច្ឆេទនៃការបង្ហាញខ្លួន ស្កេនម្រាមដៃ និងថតរូបបេក្ខជន ដែលបានដាក់ពាក្យតាមប្រព័ន្ធអនឡាញ (online) ដើម្បីចូលរួមប្រឡងប្រជែងចូលបម្រើការងារ នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

កន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការជូនដំណឹង ស្តីពីការប្រឡងជ្រើសរើសបេក្ខជនចូលបម្រើការងារ នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដល់បេក្ខជនជាមន្ត្រីរាជការ ជានិស្សិត ពីវិស័យឯកជន និង សាធារណជន តាមរយៈលិខិតលេខ ០០៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមរំលឹកជាថ្មី ចំពោះបេក្ខជនដែលបានដាក់ពាក្យចូលរួមប្រឡងប្រជែងចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ ត្រូវមកបង្ហាញខ្លួន ស្កេនម្រាមដៃ និងថតរូប ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ ចាប់ពីម៉ោង ០៨:០០ នាទី ដល់ ១១:៣០ នាទីព្រឹក និងម៉ោង ១៤:០០ នាទី ដល់ ១៧:០០ នាទីរសៀល នៅតាមទីកន្លែងដូចខាងក្រោម÷

១- នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាន់ទី២ បន្ទប់លេខ ២២
២- នៅនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ បន្ទប់ប្រជុំជាន់ទី១ អគារ “ក”
៣- នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ ជាន់ទី៩ បន្ទប់លេខ ៩០១

បេក្ខជនត្រូវភ្ជាប់មកជាមួយនូវ÷

| | |
|---|---|
| ១- ប័ណ្ណកាន់ដៃស្នើសុំប្រឡង | ចំនួន ០១ ច្បាប់ |
| ២- សញ្ញាបត្រ (បានបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច) | ចំនួន ០១ ច្បាប់ |
| ៣- អត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬសំបុត្រកំណើត ឬ សៀវភៅស្នាក់នៅ (បានបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច) | ចំនួន ០១ ច្បាប់ |
| ៤- ចំពោះបេក្ខជនជាមន្ត្រីរាជការ ត្រូវមានលិខិតបញ្ជាក់ទទួលស្គាល់ពីប្រធានក្រសួង-ស្ថាប័នសាមី ឬតំណាងដែលមានការប្រគល់សិទ្ធិ | ចំនួន ០១ ច្បាប់ |

ក្នុងករណីបេក្ខជន ខកខានពុំបានមកបង្ហាញខ្លួន ស្កេនម្រាមដៃ និងថតរូប តាមការកំណត់របស់គណៈកម្មការប្រឡងមានន័យថា បេក្ខជនបានបោះបង់សិទ្ធិក្នុងការចូលរួមប្រឡងជ្រើសរើសនេះដោយស្ម័យប្រវត្តិ។

អាស្រ័យហេតុនេះ សូមបេក្ខជនដែលបានដាក់ពាក្យចូលរួមប្រឡងប្រជែងចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អញ្ជើញមកបង្ហាញខ្លួន ស្កេនម្រាមដៃ និងថតរូប តាមពេលវេលា និងទីកន្លែងដែលបានកំណត់ខាងលើ។

Collection by VCAT Professional Consultant

**រដ្ឋលេខាធិការ**
**ប្រធានគណៈកម្មការប្រឡង**
**រដ្ឋលេខាធិការ**

**បណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798